ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ១២៤

ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ **នាមនាមប្រជារាស្ត្រខ្មែរ**

សាលដីកា **តុលាការកំពូល**

លេខ : ២៩៤ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៉ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៥-លោក | យូរ | ឧត្តរា | ជាចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី

លោក **ស៊ិន នារៈ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ**ឌិន ទិមចោ** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះជិន ហុង "រ" ម្តាយឈ្មោះសេង គីមហួរ "រ" ប្តីឈ្មោះទេព ថូ ។

មានមេធាវីលោក សោម ច័ន្ទឌីណា ជាតំណាង ។

ចុងចម្លើយឈ្មោះ **ខេន យុទ** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៧៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៣២ ក្រុមទី១១៧ មណ្ឌល៨ ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យលោក ទេព ស៊ុនថា ។

មានមេធាវីលោក ផាត់ ពៅស៊ាង ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំចំណែកលើបណ្តាំមរតករបស់លោក ទេព ថូ .

**បណ្តឹងតប** : ប្តឹងសុំបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ .

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោកសោម ច័ន្ទឌីណា ជាមេធាវីតំណាងឱ្យឈ្មោះជិន គីមហោ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមបណ្តឹងចុះថ្ងៃទី១៣-១២-២០០១ ដើមចោទ អ្នកស្រី ជិន គីមហោ ថា : ខ្លួនសុំចំណែកលើបណ្តាំមរតក របស់សពលោកតា ទេព ថូ ចុះថ្ងៃទី១១-១០-២០០១ ដែលបានប្រគល់ឱ្យខ្លួនជាប្រពន្ធ និងជាអ្នកបំរើ មើលថែលោកតា ទេព ថូ និងបានមើលថែជំងឺលោកតា ទេពថូ តាំងពីឆ្នាំ១៩៩៨ បានរស់នៅជាមួយគ្នារហូតមក ។ ក្នុងការបំរើលោកតា ទេព ថូ សព្វសារពើនេះ គាត់តែងនិយាយថា អាណិតស្រលាញ់ខ្លួនណាស់ បើគាត់ស្លាប់ទៅ មិនឱ្យខ្លួនលំបាកទេ តែខ្លួនមិនចាប់អារម្មណ៍ និងសំដីនេះឡើយ ។ នៅថ្ងៃទី១៥-១០-២០០១ លោកតាទេព ថូ បានប្រគល់ស្រោមសុំបុត្រ១មកឱ្យខ្លួន ដោយប្រាប់ថា នេះជាកេរ្តិ៍បន្តិចបន្តួច សំរាប់ឱ្យខ្លួនចិញ្ចឹមជីវិតបានដោយខ្លួនឯង នៅពេលអត់ពីគាត់ទៅ ដល់ថ្ងៃបន្ទាប់លោកតា ទេព ថូ មានជំងឺធ្ងន់ ខ្លួនក៏បញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត្រ ដល់ថ្ងៃ២៥-១១-២០០១ វេលាម៉ោង ៩:០០ព្រឹក តា ទេព ថូ ទទួលមរណៈ-ភាព ខ្លួនរៀបចំធ្វើបុណ្យតាមប្រពៃណីដោយមានញាតិមិត្ត បងប្អូនជួយជ្រោមជ្រែង ។

នៅថ្ងៃទី១១-១២-២០០១ ចៅសង្កាត់ស្រះចក បានអញ្ជើញលោកស្រី ពេន យុត ដែលជាប្រពន្ធមុន បានបួសនៅវត្តតាំងពី១០ឆ្នាំមកហើយ និងកូនដើមរបស់តា ទេព ថូ ចំនួន០៣នាក់ មកស្តាប់នូវសេចក្តីមរតក ពួកគាត់យល់ព្រមតាមសេចក្តីនេះដោយទទួលស្គាល់ថា ពិតជាអក្សររបស់លោកតា ទេព ថូ មែន ដូចមានកំណត់ហេតុរបស់ចៅសង្កាត់ស្រះចកស្រាប់ ដោយខ្លួនជួបការលំបាក ខ្វះថវិកា ខ្លួនសុំឱ្យតុលាការសំរេចតាមបណ្តាំ ចុះថ្ងៃទី១១-១០-២០០១ របស់លោកតា ទេព ថូ ។

តាមបណ្តឹងតបចុះថ្ងៃទី០៨-០២-២០០២ លោក ទេព ស៊ុនថា តំណាងឱ្យលោកយាយ ពេន យុត (ប្រពន្ធសព) ថា ខ្លួន និងបង១៦នាក់ទៀត មានឈ្មោះ ទេព ណាត,ទេព ណុល ,

ទេព មុន្នី, ទេព វង្សី, ទេព វង្សិ, ទេព វង្សា ដែលត្រូវជាកូនបង្កើតរបស់សពលោកតាទេព ថូ និងជាទាយាទ សូមប្ដឹងបដិសេធលិខិតចែកមរតក ចុះថ្ងៃទី១១-១០-២០០១ ដែលភាគីដើមចោទប្ដឹងទាមទារ ដោយហេតុថា លិខិតនេះ បានធ្វើឱ្យខូចខាតសិទ្ធិជាទាយាទក្នុងការទទួលមរតក និងធ្វើឱ្យបាត់នូវចំណែករបស់ពួកខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងសុំ និងចម្លើយប្ដឹងសុំរបស់លោកយាយ ពេន យុត និងលោក ទេព ស៊ិនថា ជាតំណាងទាយាទនៃសពលោក ទេព ថូ ដែលមានលោកមេធាវីផាត់ពៅ-ស៊ាង ចំណាយក្ដីផង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹង និងចម្លើយតវ៉ារបស់អ្នកស្រីជិន គីមហោ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជិន សុផល មានមេធាវីសោម ច័ន្ទឪណា និងការ សាវុត្ថ ចំណាយក្ដីផង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈនូវលិខិតបណ្ដាំចែកមរតក ចុះថ្ងៃទី១១-១០-២០០១ របស់សពលោក ទេព ថូ តាមគោលការណ៍ច្បាប់ ។

៤-បង្គាប់ឱ្យអ្នកស្រី ជិន គីមហោ ចែកផ្ទះលេខ ៣៣AE1 ,ស្ថិតនៅផ្លូវលេខ ៣៣៦ ភូមិ១ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ពាក់កណ្ដាលឱ្យមកទាយាទនៃសពលោកទេព ថូ មានលោក ទេព ស៊ិនថា ជាតំណាង មានមេធាវីផាត់ ពៅស៊ាង ចំណាយក្ដីផង ។ បើចែកមិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកជាពីរភាគស្មើ(មាត្រា ១៦៨ និងតទៅនៃច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ) ។

៥-បង្គាប់ឱ្យឈ្មោះនាងជិន នាងអ៊ីម និង លោក លី សុវណ្ណារ៉ា និងគ្រួសារព្រមទាំងអ្នកដទៃទៀត ចុះចេញពីផ្ទះលេខ៣៣AE1 ភូមិ១ សង្កាត់ផ្សារដើមគរ ។

៦-ទុកជាមោឃៈនូវលិខិតលក់ដី ផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១២-៤-២០០១ នូវដីទំហំ ៤៧៥០ម$^{២}$ តំលៃ ២៨៥០៛ និងលិខិតលក់ដីផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៨-១០-២០០១ ទំហំ ៧៨៨៥ម$^{២}$ តំលៃ ៤.៧៣១៛ ដែលស្ថិតនៅភូមិព្រៃជ្រាយក្របៅ២ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាមពីឈ្មោះអ្នកស្រី ជិន គីមហោ ឱ្យទៅឈ្មោះទូច ចំរើន និងប្រពន្ធ ជិន សុផល (មាត្រា១៦៨ និង ១៧១ នៃច្បាប់ភូមិបាលថ្មី និងមាត្រា ៣៩ នៃច្បាប់កិច្ចសន្យាលេខ ៣៨) ។

៧-បង្គាប់ឱ្យអ្នកស្រី ជិន គីមហោ ផ្ទេរសិទ្ធិឱ្យអ្នកស្រី ជិន សុផល មានមេធាវីសោម ច័ន្ទឪណា និងការ សាវុត្ថ ចំណាយក្ដីផង ចែកដីទំហំ ៤៧៥០ម$^{២}$ តម្លៃ ២.៨៥០៛ ដែល

ទិញពីអ្នកស្រីឈាវ គឹមសា តាមលិខិតលក់ដីផ្ទេរកម្មសិទ្ធិកាន់កាប់ចុះថ្ងៃទី១៤-៤-២០០១ ពាក់កណ្តាលឱ្យទៅទាយាទ នៃសពលោកទេព ថូ និងដីទំហំ ៧៨៨៥ ម² ដែលទិញពីឈ្មោះឈាវ វ៉ា ប្រពន្ធឈ្មោះវួច ស៊ឹម តំលៃ ៤.៧៣១$ ដែលទិញតាមលិខិតលក់ដីផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី១២-៤-២០០១ ស្ថិតនៅភូមិជ្រោយក្របៅ២ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម ពាក់កណ្តាលឱ្យទៅទាយាទនៃសពលោក ទេព ថូ ។ បើចែកគ្នា មិនដាច់ស្រេចឱ្យលក់ឡាយឡុងយកប្រាក់ចែកគ្នាស្មើ ចាប់ពីពេលដែលសាលក្រមនេះ ស្ថាពរ (មាត្រា១៦៨-១៧១ នៃច្បាប់ភូមិបាលថ្មី) ។

៨-ឱ្យអ្នកស្រី ជិន គឹមហោ បង់ប្រាក់ប្រដាប់ក្តី ២១.០០០៛ ដែលបានកាត់យកពីប្រាក់ប្រដាប់ក្តីរបស់ទាយាទនៃសពលោកទេព ថូ ក្នុងសំណុំរឿងលេខ ១៩៣៣ ចុះថ្ងៃទី១៩-១២-២០០១ និងសំណុំរឿងលេខ ១២២ ចុះថ្ងៃទី២៣-០១-២០០២ ចំនួន ១៤.០០០៛ និងសំណុំរឿងលេខ ១៩២៥/១៨-១២-២០០១ ចំនួន ៧.០០០៛ របស់អ្នកស្រីជិន គឹមហោ ដាក់ថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ និងឱ្យអ្នកស្រី ជិន គឹមហោ មានអ្នកស្រីជិន សុផល ជាតំណាងបង់ពន្ធសមាមាត្រ១% នៃតម្លៃនៃរឿងក្តីនេះ តែត្រូវឱ្យអ្នកឈ្នះក្តីបង់ជាមុន ហើយតម្រូវឱ្យអ្នកស្រី ជិន គឹមហោ សងប្រាក់ប្រដាប់ក្តីចំនួន ១៤.០០០៛ និងប្រាក់ពន្ធសមាមាត្រនេះទៅទាយាទនៃសពលោកទេព ថូ វិញ ។

៩-សាលក្រមនេះ សម្រេចសេចក្តី និងប្រកាសជាសាធារណៈ ចំពោះមុខជិន-សុផល មេធាវីសោម ច័ន្ទឌីណា លោក ទេព ស៊ុនថា មេធាវីផាត់ ពៅស៊ាង បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃសម្រេចសេចក្តី ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ខែមិថុនា ឆ្នាំ២០០៣ របស់លោក សោម ច័ន្ទឌីណា តំណាងឱ្យអ្នកស្រី ជិន គឹមហោ មិនសុខចិត្តនឹងសាលក្រមលេខ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២៩"ឈ" ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៦-២០០៣ របស់លោកមេធាវីសោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៨"ក" ចុះថ្ងៃទី១២-៥-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះពេន យុត បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ២៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះជិន គីមហោ សងប្រាក់ ១៣.០០០រនេះ ឱ្យទៅឈ្មោះពេន យុត វិញ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦-៨-២០០៣ ចំពោះមុខតំណាងចុងចម្លើយ និងមេធាវីចុងចម្លើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-៩-២០០៣ កំបាំងមុខគូក្តី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១១៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៣ របស់លោកសោម ច័ន្ទឌីណា មេធាវីចំណាយក្តីឱ្យដើមចោទ ប្តឹងទាស់នឹងសាលដីការដ្ឋប្បវេណីលេខ១២៩"ឈ" ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី៣០-៩-២០០៣ របស់លោកមេធាវី សោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១២៩"ឈ"ចុះថ្ងៃទី០៥-៩-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៨-១១-២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-១២-២០០៣ ចំពោះមុខមេធាវីតំណាងចុងចម្លើយ កំបាំងមុខមេធាវីតំណាងដើមចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោកសោម ច័ន្ទឌីណា ជាមេធាវីតំណាងឱ្យឈ្មោះជិន គីមហោ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះជិន គីមហោ

បានឃើញសារណាតបចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះពេន យុត ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ"ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អ្នកស្រី ជិន គឹមហោ នៅពេលសវនាការ ។

បានស្តាប់ចម្លើយរបស់លោកទេព ស៊ុនថា តំណាងឱ្យអ្នកស្រីពេន យុត ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា : ចំពោះបណ្តាំមរតក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ចំពោះខ្លួន និងក្រុមគ្រួសារ ខ្លួនគិតថា មិនត្រឹមត្រូវទេ ហើយក្រុមគ្រួសារទាំងមូលមិនមានអ្នកណាម្នាក់បានដឹងទាល់តែសោះ ។ ចំពោះខ្លួន អ្នកស្រីជិន គឹមហោ មិនមែនជាប្រពន្ធរបស់ឪពុកខ្លួនទេ អ្នកស្រីជិន គឹមហោ គាត់ទទួលប្រាក់ខែពីឪពុករបស់ខ្លួន ព្រោះថាជាកាតព្វកិច្ច ដូចជា ការបោកគ្លកអាចម៍នោម គឺជាភារកិច្ចរបស់អ្នកស្រីជិន គឹមហោ ព្រោះអ្នកស្រីជិន គឹមហោ ជាអ្នកបំរើរបស់ឪពុកខ្លួន។ ម៉្យាងទៀត អ្នកស្រី ជិន គឹមហោ គាត់បានទទួលចំណែកពាក់កណ្តាលហើយ នៅមានដីជាច្រើនកន្លែងទៀតដែលក្រុមគ្រួសារខ្លួនមិនទាន់បានរកឃើញ ។ ខ្លួនសូមតំកល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសោម ច័ន្ទឌីណា ជាមេធាវីការពារ និងតំណាងឱ្យអ្នកស្រីជិន គឹមហោ ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា :បើពិនិត្យលើបណ្តាំមរតកមួយច្បាប់ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ គឺជាសំណេរអក្សរផ្ទាល់ដៃរបស់ឈ្មោះទេព ថូ ដែលជាម្ចាស់ទ្រព្យដោយបានសរសេរដោយផ្ទាល់ដៃ ក្នុងលិខិតបណ្តាំនេះ បានសរសេរយ៉ាងច្បាស់លាស់អំពីឈ្មោះរបស់ម្ចាស់ទ្រព្យ ហើយបានបញ្ជាក់ពីគោលបំណងដែលម្ចាស់បណ្តាំចង់ប្រគល់អោយ ។ លោកតាទេព ថូ បានធ្វើការបែងចែកជាពីរចំណែកយ៉ាងច្បាស់លាស់ គឺទី១ លោកយាយពេនយុត ទី២ គឺកូនក្តីខ្លួន តាមការបែងចែកលោកតាទេព ថូ បានបញ្ជាក់ពីទីកន្លែង និងប្រវែងច្បាស់លាស់ ទី៣ ទៀតលិខិតបណ្តាំនេះ បានចុះថ្ងៃ ខែ ឆ្នាំ និងបានចុះហត្ថលេខា និងមានស្នាមមេដៃបញ្ជាក់យ៉ាងច្បាស់លាស់ ។ លិខិតបណ្តាំនេះ បានដាក់ក្នុងស្រោមត្រឹមត្រូវហើយ លោកតាទេព ថូ បានប្រគល់ឱ្យចៅសង្កាត់ឈ្មោះ ឆាយ ធីរិទ្ធិ ដោយបានចុះលេខរដ្ឋបាលយ៉ាងត្រឹមត្រូវ ។ បើសិនជាពិនិត្យលើអត្ថបទច្បាប់វិញ បណ្តាំមរតក គឺជាសន្តតិកម្ម ដែលជាការផ្ទេរនូវបេតិកភ័ណ្ឌនៃបុគ្គលដែលស្លាប់ឱ្យជនម្នាក់ ឬច្រើននាក់ ដែលរស់នៅ ហៅថា សន្តតិជន ។ ការផ្ទេរនេះ គឺធ្វើទៅតាមឆន្ទៈរបស់ម្ចាស់ទ្រព្យ ។ ខ្លួនសំណូមពរ សូមឯកឧត្តមប្រធានតុលាការកំពូល លោកចៅក្រមមេត្តាផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួន ដោយបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសារជាថ្មីឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកផាត់ ពៅស៊ាង ជាមេធាវីការពារឱ្យចុងចំលើយ បានធ្វើសេចក្តីសន្និដ្ឋានថា : ខ្លួនសូមជំរាបថា អ្នកស្រីជិន គីមហោ មិនមែនជាប្រពន្ធរបស់សពលោកតាទេព ថ្វ ទេ គឺជាអ្នកបំរើក្នុងមួយខែ ១០០ដុល្លារអាមេរិក អ្នកស្រីជិន គីមហោ គាត់បំរើតបស្នងទៅលោកតាទេព ថ្វ វិញ ព្រោះអ្នកស្រីជិន គីមហោ ទទួលប្រាក់ ១០០ដុល្លារអាមេរិក ក្នុងឋានៈអ្នកស្រីជិន គីមហោ បំរើមនុស្សចាស់ ។ ដ្បិតញបណ្តាំមរតកសរសេរនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ លោកតាទេពថ្វ មានសតិអារម្មណ៍មិនហ្គឹងនរ ។ តាមគតិច្បាប់ការបែងចែកមរតកសាស្ត្រសន្តតិជនដំបូងគេបង្អស់គឺកូន កូនមិនបានទទួលបែរជាអ្នកស្រីជិន គីមហោ បានទទួលពាក់កណ្តាលទៅវិញ គាត់មិនបែងចែកឱ្យទៅទាយាទ គឺជាមោឃភាពរបស់បណ្តាំមរតក។បណ្តាំមរតកសរសេរនៅក្នុងសតិវិលវល់ ។ ចំណែកផ្ទះលេខ៣៣AE1 មានស្លាកមេដៃរបស់លោកតាទេព ថ្វ និងដីពីរកន្លែងទៀត ក៏ដាក់ឈ្មោះលោកតា ទេព ថ្វ ទៀត បើលោកតា ទេព ថ្វ មិនចេញប្រាក់ទេ ហេតុអ្វីបានដាក់ឈ្មោះលោកតា ទេព ថ្វ ។ ខ្លួនសូមសំណូមពរក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍លេខ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណាដើមចោទ ចម្លើយតំណាងចុងចម្លើយ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៤ របស់លោកមេធាវី សោម ច័ន្ទឱណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលមេធាវីដើមចោទ លើកឡើងនៅពេលសវនាការនេះថា មរតកសាសន៍ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ធ្វើឡើងតាមគន្លងច្បាប់ជាលិខិតបណ្តាំ ធ្វើក្រោយគេ ហើយជាប្រភេទលិខិតបណ្តាំឯកជន សរសេរដោយដៃម្ចាស់ទ្រព្យផ្ទាល់ដែលគប្បីមានអានុភាពតាមផ្លូវច្បាប់ ហើយថា បើទោះបីជាអ្នកស្រីជិន គីមហោ មិនមែនជាសហព័ទ្ធរបស់សពលោកតាទេព ថ្វ ក៏អ្នកស្រីអាចទទួលអច្ច័យទានបានដែរ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា បច្ចុប្បន្នយើងពុំទាន់មានច្បាប់ស្តីពីមរតកទេ ហើយតាមលិខិត ចុះថ្ងៃទី១៤-០២-២០០១ របស់សព បាន

បញ្ជាក់ច្បាស់ថា បានប្រគល់ផ្ទះចែកកូន៧នាក់ ដោយមានតម្លៃតបស្នងផង ។ ម៉្យាងទៀត បណ្ដាំចុះថ្ងៃទី១១-១០-២០០១ ធ្វើឡើងពេលដែលលោកតាទេពថូ មានជំងឺធ្ងន់ ហើយខ្លឹមសារនៃលិខិតបណ្ដាំចុះថ្ងៃទី១១-១០-២០០១នេះ ពុំបានចែងថា ឱ្យលុបចោលនូវបណ្ដាំមុន១ទេ ។

- យល់ឃើញថា តុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ពុំបានទទួលស្គាល់អ្នកស្រីជិន គឹមហោ ជាសហព័ទ្ធស្របច្បាប់របស់សពលោកតា ទេព ថូ ឡើយ តែបែរជាទទួលស្គាល់ផ្ទះលេខ ៣៣ AE1 ស្ថិតនៅផ្សារដើមគរ និងដីនៅស្រុកកងមាស ខេត្តកំពង់ចាម ដោយសំអាងលើលិខិតផ្ទេរសិទ្ធិមានឈ្មោះអ្នកស្រី ជិន គឹមហោ និងសពលោកតា ទេព ថូ ជាទ្រព្យរួមនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា បុគ្គលពីរនាក់ដែលមិនមែនជាសហព័ទ្ធនឹងគ្នា មានសិទ្ធិលើវត្ថុតែមួយ មិនអាចមានន័យថា ជាទ្រព្យរួមឡើយ ។

- យល់ឃើញថា ដើមចោទ បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះ កំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧៦"ឈ"ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ហើយ លើកលែងតែចំណុចទី៤,៥,៦,៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ត្រូវទុកជាមោឃៈ ។

**ដោយហេតុដូច្នេះ**

**ជំនុំជំរះសំរេចសេចក្ដីចំពោះមុខដំណាក់កាលចុងក្រោយ**

**កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្ដឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី សោម ច័ន្ទនីណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ១៧៦"ឈ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី៤,៥,៦, និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចទី៤,៥,៦ និងទី៧ នៃសាលក្រមរបស់តុលាការក្រុងភ្នំពេញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រីពេន យុត បានបង់នៅតុលាការកំពូល ចំនួន

១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លិងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០រៀល

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ។